ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៧/១២-កិស គ្លូរី
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ ឈីវ ភិរម្យ

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ គង់ ផល្លៈ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន គិស គ្លូរី (ខេមបូឌា) ខេនូហ្វេកឈ័ររីង**

អាសយដ្ឋាន ៖ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៧ ៨៨៨ ៨ ២៥១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក Piao Young Qi | នាយកក្រុមហ៊ុន |
| ២- លោក យ៉ាង សុខុម | បុគ្គលិកផ្នែកច្បាប់ |
| ៣- កញ្ញា ឡេង សុជាតា | ប្រធានបុគ្គលិក |
| ៤- លោក ជា សុផល | រដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សហព័ន្ធសហជីពកម្មករនិយោជិត**

- **សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន គិស គ្លូរី**
- **សហជីពស្មារតីកម្មករនិយោជិតនៃក្រុមហ៊ុន គិស គ្លូរី**

អាសយដ្ឋាន ៖ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៩៩៥ ៥២៣ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក លី វេង ប្រធានសហព័ន្ធសហជីពកម្មករនិយោជិត

២- លោក រឹក ចាន់ណា ប្រធានសហជីពស្មារតីកម្មករនិយោជិតនៃក្រុមហ៊ុន ភិសគ្គូរី

៣- លោក កែវ វ៉េន ប្រធានសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ភិសគ្គូរី

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- នៅពេលកម្មករធ្វើការថែមម៉ោងថ្ងៃបុណ្យ និងថ្ងៃអាទិត្យទាមទារឱ្យក្រុមហ៊ុនផ្តល់លុយបាយចំនួន ២០០០ រៀល ឬបាយមួយពេល។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ ប៉ុន្តែក្រុមហ៊ុនបានផ្តល់ប្រាក់ឈ្នួលធ្វើការថ្ងៃបុណ្យ និងថ្ងៃអាទិត្យដោយអនុវត្តទៅតាមច្បាប់ស្តីពីការងារ ។

២- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដោយចែកជាសមាមាត្រចំនួន ១២ ខែមកគណនា ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ឱ្យតាមប្រាក់ឈ្នួលគោល ឬឱ្យឈប់សម្រាក ។

៣- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោល ១០០ ភាគរយ នៅពេលដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើរយៈពេលតិចជាង១៣ ថ្ងៃ បើលើស ១៣ ថ្ងៃ ត្រូវផ្តល់ឱ្យចំនួន ៥០ ភាគរយ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា នៅពេលកម្មករមកធ្វើការក្រុមហ៊ុនគ្មានការងារធ្វើមួយថ្ងៃដំបូងឱ្យប្រាក់ឈ្នួល ១០០ ភាគរយ បន្ទាប់មកឈប់សម្រាកនៅផ្ទះរយៈពេលខ្លី ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលឱ្យ ៥០ ភាគរយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០៧៩ កប/អក/វក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ ។

THE ARBITRATION COUNCIL

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្មករនិយោជិត លេខ ១៨៩/១១ សសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១៦ ចំណុច លើការទាមទារចំនួន ១៩ ចំណុច។ ចំណុចមិនសះជាចំនួន ០៣ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ តាមរយៈរបាយការណ៍ ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ០៧៩ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច គឺចំណុចវិវាទទី១ និងទី៣។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាតែចំណុចវិវាទទី២ ប៉ុណ្ណោះ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើ ចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេចដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សរណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីផលប្រយោជន៍។

ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លើចំណុចវិវាទអំពីផលប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេច ដែលជាវិវាទអំពីសិទ្ធិទេ។

ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ ។

នៅក្នុងសំណុំរឿងនេះ ភាគីវិវាទបានជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច លើវិវាទអំពីផលប្រយោជន៍ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លក្ខន្តិកៈក្រុមហ៊ុន ភិស គ្លូរី ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ។

២- តារាងបើកប្រាក់បំណាច់ឆ្នាំសម្រាប់កម្មករនិយោជិតចូលបំរើការងារពេញមួយឆ្នាំ ២០១១ ។

៣- កំណត់ហេតុប្រជុំស្តីពីការផ្តល់ជាប្រាក់ជូសការឈប់សម្រាកប្រចាំឆ្នាំរបស់បុគ្គលិក កម្មករ កម្មការិនីនៅក្រុមហ៊ុន ភិស គ្លូរី ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៨ ។

៤- កំណត់ហេតុប្រជុំស្តីពីការផ្តល់ជាប្រាក់ជូសការឈប់សម្រាកប្រចាំឆ្នាំរបស់បុគ្គលិក កម្មករ កម្មការិនីនៅក្រុមហ៊ុន ភិស គ្លូរី ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៧ ។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ភិស គ្លូរី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ។

៦- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ភិស គ្លូរី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ។

៧- ប័ណ្ណប៉ាតង់ឆ្នាំ២០១១ ក្រុមហ៊ុន ភិសគ្លូរី ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ។

៨- វិញ្ញាបនប័ត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ភិស គ្លូរី ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ។

៩- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតំលៃបន្ថែម ក្រុមហ៊ុន ភិស គ្លូរី ចុះឆ្នាំ២០០៧ ។

១០- វិញ្ញាបនប័ត្របញ្ជាក់ជាសមាជិកសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ក្រុមហ៊ុន ភិស គ្លូរី ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ។

១១- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្រុមហ៊ុន ភិសគ្លូរី ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ។

១២- លិខិតអនុញ្ញាតឱ្យដាក់តាំងផ្សព្វផ្សាយពាណិជ្ជកម្មយីហោ ភិស គ្លូរី ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ។

១៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន ភិសគ្លូរី ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ភិសគ្លូរី លេខ ០៧៥ កប/អក/វក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ភិសគ្លូរី ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១១៣ កប/អក/វក/លកអ. ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១១៤ កប/អក/វក/លកអ. ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ ។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ភិស គ្លូរី (ខេមបូឌា) មេនូហ្វេកឈ័ររីង គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ មានជួលកម្មករនិយោជិតសរុប ចំនួន ១១០០ នាក់។
- សហជីពកម្មករនិយោជិត និងសហជីពស្មារតីកម្មករនិយោជិត គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពទាំងពីរនេះមានសមាជិកសរុបចំនួន ៤៩០ នាក់។

ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់បំណាច់ជូសការឈប់សម្រាកប្រចាំឆ្នាំ ដោយចែកជាសមមាត្រ ចំនួន ១២ ខែ មកគណនា

- ការអនុវត្តរបស់ក្រុមហ៊ុន គឺរាល់ពេល ដែលបញ្ចប់កិច្ចសន្យាការងារ គឺនិយោជកបានទូទាត់ប្រាក់បំណាច់ជូសការឈប់សម្រាកប្រចាំឆ្នាំជូនកម្មករនិយោជិត ដោយយកប្រាក់ឈ្នួលគោលមកធ្វើជាមូលដ្ឋានក្នុងការគណនា។
- ភាគីកម្មករនិយោជិតមិនយល់ព្រមតាមការអនុវត្តរបស់និយោជកទេ គឺសុំឱ្យនិយោជកយកប្រាក់ឈ្នួលសរុបចំនួន ១២ ខែ ចុងក្រោយ មុនការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត មកធ្វើជាមូលដ្ឋានក្នុងការគណនាប្រាក់បំណាច់ជូសការឈប់សម្រាកប្រចាំឆ្នាំ ។

THE ARBITRATION COUNCIL

- នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតមិនបានដឹងថា តើកន្លងមក និយោជកធ្លាប់គិតប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដោយយកប្រាក់ឈ្នួលគោល ជូនកម្មករនិយោជិតបានចំនួនប៉ុន្មាននាក់ទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីកម្មករនិយោជិតដាក់បង្ហាញភស្តុតាងពីចំនួនកម្មករនិយោជិត ដែលនិយោជកធ្លាប់ទូទាត់នេះដែរ ប៉ុន្តែ ដល់កំណត់កាលបរិច្ឆេទ ភាគីកម្មករនិយោជិតពុំបានផ្ញើរភស្តុតាងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមកាលកំណត់ទេ។ យ៉ាងណាមិញ និយោជកក៏មានបានបដិសេធថា គ្មានករណីនេះកើតឡើងដែរ។ ពោល គឺភាគីទាំងពីរទទួលស្គាល់នូវការអនុវត្តការយកប្រាក់ឈ្នួលគោល មកធ្វើជាមូលដ្ឋានក្នុងការគណនាប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ។
- ភាគីនិយោជកពុំបានយល់ព្រមតាមការទាមទារនេះទេ។
- នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រង់ប្រការ ៤ បានលើកឡើងថា "*និយោជិតកម្មករទាំងអស់ត្រូវបំពេញការងារចំនួន ៨ ម៉ោង ក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោង ក្នុងមួយសប្តាហ៍...ការឈប់សំរាកប្រចាំសប្តាហ៍ : ឈប់មួយថ្ងៃអាទិត្យពេញ...*"។ ដូចនេះ កម្មករនិយោជិតធ្វើការ ៦ ថ្ងៃ ក្នុងមួយសប្តាហ៍ ហើយ ២៦ ថ្ងៃ ក្នុងមួយខែ។

**ហេតុផលនៃសេចក្តីសម្រេច:**

មុននឹងពិចារណាចំណុចទាមទារទាំងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះជា វិវាទអំពីសិទ្ធិដែរ ឬទេ ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយចែងពីការទាមទារនោះ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ០៥/១១-អ៊ីម វើ (សាខាទី១) ហេតុផលចំណុចវិវាទទី១&៥ និងលេខ ១៧/១១-ហ្គូលកាំវីម៉ិច* ហេតុផលចំណុចវិវាទទី១ *និងទី២)* ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទទី២នេះ គឺជាវិវាទអំពីសិទ្ធិ ព្រោះរបៀបនៃការទូទាត់ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ នៅពេលដែលកិច្ចសន្យាការងាររបស់កម្មករនិយោជិត និង និយោជកត្រូវបានបញ្ចប់ មានចែងនៅក្នុងច្បាប់ស្តីពីការងារ។

**ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដោយចែកជាសមមាត្រ ចំនួន ១២ ខែ មកគណនា**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានកាតព្វកិច្ចគិតប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដោយយកប្រាក់ឈ្នួលសរុប ចំនួន ១២ ខែ ចុងក្រោយ មុនការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតមកធ្វើជាមូលដ្ឋានក្នុងការគណនាដែរ ឬទេ?

មាត្រា ១៦៨ នៃច្បាប់ស្តីពីការងារ ដែលទាក់ទងទៅនឹងការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួល ចែងថា "*និយោជកត្រូវបង់ឱ្យកម្មករនិយោជិតនៅពេលមុនថ្ងៃឈប់សំរាកនូវប្រាក់វិភាជន៍ យ៉ាងហោចណាស់ស្មើនឹង*

THE ARBITRATION COUNCIL

*ចំនួនមធ្យមនៃប្រាក់ឈ្នួល បុព្វលាភ វិភាជន៍ អត្ថប្រយោជន៍ បំណាច់ គិតទាំងតម្លៃវត្ថុ ដែលផ្តល់ឱ្យផង ដោយមិនគិតពីបំណាច់សងសោហ៊ុយ ដែលកម្មករនិយោជិតបានបើករួចមកហើយក្នុងពេលដប់ពីរខែមុនថ្ងៃឈប់សំរាក។ ប្រាក់វិភាជន៍នេះ ក្នុងករណីណាក៏ដោយ មិនត្រូវឱ្យតិចជាងវិភាជន៍ ដែលកម្មករនិយោជិតត្រូវបើកកាលបើខ្លួនបានធ្វើការដោយទៀងទាត់នោះឡើយ "*។

តាមន័យនៃមាត្រាខាងលើនេះ ក្នុងករណីដែលមានការបញ្ចប់កិច្ចសន្យាការងារ និយោជកត្រូវប្រើមូលដ្ឋានចំនួនមធ្យមនៃប្រាក់ឈ្នួលបុព្វលាភ វិភាជន៍ អត្ថប្រយោជន៍ បំណាច់ គិតទាំងតម្លៃវត្ថុ ដែលផ្តល់ឱ្យកម្មករនិយោជិតផង ក្នុងរយៈពេលដប់ពីរខែ មុនថ្ងៃឈប់សម្រាក។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចឱ្យនិយោជកធ្វើការទូទាត់ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដោយយកប្រាក់ឈ្នួលសរុបនៃរយៈពេលដប់ពីរខែចុងក្រោយ ដែលកម្មករនិយោជិតធ្វើបាន មកចែកនឹងដប់ពីរ ដើម្បីរកប្រាក់ឈ្នួលមធ្យមក្នុងមួយខែ។ បន្ទាប់មកយកប្រាក់ឈ្នួលមធ្យមក្នុងមួយខែនេះមកចែកនឹង ២៦ ដើម្បីរកប្រាក់ឈ្នួលមធ្យមក្នុងមួយថ្ងៃ មកគុណនឹងការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលរបស់ពួកគាត់ដែលនៅសល់។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ២៧/០៤-អឹម អេស ហេតុផលចំណុចវិវាទទី៣ និង លេខ ៩៤/០៧-ហ្វូរធ្យូន ហ្គាមេន ហេតុផលចំណុចវិវាទទី២*)។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយក្នុងសំណុំរឿងខាងលើៗដែរ។

តាមរយៈការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកបានទូទាត់ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដោយយកប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិត មកធ្វើជាមូលដ្ឋានក្នុងការគណនា។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជក ពុំស្របទៅតាមមាត្រា ១៦៨ នៃច្បាប់ស្តីពីការងារ និងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗនៅឡើយទេ។

ដូចនេះ តាមរយៈអង្គហេតុ កម្មករនិយោជិតធ្វើការ ៦ ថ្ងៃ ក្នុងមួយសប្តាហ៍ ហើយ ២៦ ថ្ងៃ ក្នុងមួយខែ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកយកប្រាក់ឈ្នួលសរុបចំនួន ១២ ខែ ចុងក្រោយ មុនការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត មកចែករកជាមធ្យមភាគក្នុងមួយខែ បន្ទាប់មកយកប្រាក់ឈ្នួលមធ្យមក្នុងមួយខែនេះ មកចែកនឹង ២៦ (ចំនួនថ្ងៃដែលកម្មករនិយោជិតធ្វើការក្នុងមួយខែ) ដើម្បីរកប្រាក់ឈ្នួលជាមធ្យមក្នុងមួយថ្ងៃ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

### ១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:

**ចំណុចវិវាទទី ២ ៖**

បង្គាប់ឱ្យនិយោជកយកប្រាក់ឈ្នួលសរុបចំនួន ១២ ខែ ចុងក្រោយ មុនការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត មកធ្វើជាមូលដ្ឋានគណនាប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំ។

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០ ។

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ÷ គ្មាន**

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **ឈឹម គិរមុំ**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អេន ណាន**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ----------------------------------------

THE ARBITRATION COUNCIL